# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៨ អនក្រ

## សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការចំរុះ

## អន្តរក្រសួងរៀបចំដាក់ផ្សាយបំណុលរតនាគារ

**************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ : នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ: ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ : ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ :នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ: នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

- បានឃើញសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ៨៦ សសរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងទទួលបន្ទុករៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- បានឃើញអនុក្រឹត្យលេខ : ០៨ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩៧ ស្ដីពីការដាក់ផ្សាយប័ណ្ណរតនាគារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## **សំរេច**

**ប្រការ១** : ត្រូវបានកែសំរួលសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារដែលមានចែងក្នុងប្រការ១នៃសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលលេខ :៨៦ សសរចុះថ្ងៃទី ១២ខែ ធ្នូឆ្នាំ១៩៩៥ ដូចខាងក្រោម :

១- ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រធាន

២- ឯកឧត្តមទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា ជាអនុប្រធាន

៣- ឯកឧត្តមអគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ជាសមាជិកអចិន្ត្រៃយ៍

៤- លោកប្រធានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៥- លោកប្រធាននាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា ជាសមាជិក

៦- លោកប្រធាននាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៧- លោកប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៨- លោកប្រធាននាយកដ្ឋានវិភាគនិងព្យាករណ៍សេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក ។

**ប្រការ២**: ចំពោះខ្លឹមសារនៃប្រការដទៃទៀតនៃសេចក្ដីសំរេចលេខ ៨៦ សសរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលនៅរក្សាទុកដដែល ។

**ប្រការ៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
  ដើម្បីជូនជ្រាប
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- រតនាគារជាតិ
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ